**កម្មវត្ថុ៖ ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន – កិច្ចប្រជុំដោយផ្ទាល់និងតាមអនឡាញ – ថ្ងៃទី 9 ខែមករា ឆ្នាំ 2025**

ភាគីពាក់ព័ន្ធយុត្តិធម៌បរិស្ថានទាំងអស់ជាទីគោរព!

ការិយាល័យប្រតិបត្តិកិច្ចការថាមពល និងបរិស្ថាន (EEA) នឹងរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC) បន្ទាប់របស់ខ្លួននៅ **ថ្ងៃព្រហស្បតិ៍ ទី 9 ខែមករា ឆ្នាំ 2025 វេលាម៉ោង 6:30 ល្ងាច**។ សមាជិកក្រុមប្រឹក្សានឹងមានការពិភាក្សាអំពីកម្មវិធីទាក់ទងនឹងភាពធន់របស់ឆ្នេរ (ResilientCoast) និងទំនប់វារីអគ្គិសនីដែលបញ្ជាក់ដោយវិទ្យាស្ថានវាយតម្លៃគម្រោងវារីអគ្គិសនីដើម្បីធានានូវផលប៉ះពាល់ទាប (Low Impact Hydropower Institute)។ ពេលវេលាមួយចំនួននឹងត្រូវបានបែងចែកក្នុងអំឡុងពេលកិច្ចប្រជុំសម្រាប់មតិយោបល់ទូទៅពីសាធារណជន។

**សូមចុះឈ្មោះសម្រាប់កិច្ចប្រជុំតាមរយៈតំណភ្ជាប់នេះ៖**
https://www.zoomgov.com/webinar/register/WN_AnO1_tpmRDSqgAAKu5gslg

**ការរៀបចំកិច្ចប្រជុំ៖** កិច្ចប្រជុំទម្រង់កូនកាត់នេះនឹងត្រូវបានរៀបចំឡើងទាំងតាមអនឡាញនៅលើ Zoom និងដោយផ្ទាល់ក្នុងទីក្រុង Lowell រដ្ឋ MA នៅសាកលវិទ្យាល័យ University of Massachusetts ទីក្រុង Lowell ក្នុងសាល Coburn Hall។ កិច្ចប្រជុំនេះត្រូវបានប៉ាន់ស្មានថាមានរយៈពេល 90 នាទី។ អាសយដ្ឋានគឺ 850 Broadway St, Lowell, MA, 01854 ហើយអាចចូលទៅអគារនេះបានដោយប្រើរថយន្តក្រុងខ្សែលេខ 17, 5 និង 6។ ទីតាំងនេះក៏អាចចូលបានតាមរយៈខ្សែរថភ្លើង Lowell Line Commuter Rail MBTA ផងដែរ។ ចំណតរថយន្តក្រុងដែលនៅជិតបំផុតគឺ Broadway St និង Walker St។ កន្លែងចតរថយន្តមាននៅក្នុងចំណតរបស់ភ្ញៀវ។

**ការគាំទ្រផ្នែកបកប្រែភាសា៖** សេវាបកប្រែភាសាផ្ទាល់មាត់នឹងមានផ្តល់ជូនដោយផ្ទាល់ ជាភាសាអេស្ប៉ាញ ព័រទុយហ្គាល់ វៀតណាម និងខ្មែរ។ ការបកប្រែផ្ទាល់មាត់តាមអនឡាញនឹងរួមមាន ភាសាអេស្ប៉ាញ ព័រទុយហ្គាល់ ចិនកុកងឺ វៀតណាម ក្រេអូលហៃទី កាប់វែរ ខ្មែរ និងភាសាសញ្ញាអាមេរិក (ASL)។ ប្រសិនបើអ្នកត្រូវការការបកប្រែផ្ទាល់មាត់ជាភាសាដែលមិនបានបញ្ជាក់ខាងលើ ឬការសម្របសម្រួលបន្ថែមណាមួយ សូមបញ្ជូលសំណើនោះក្នុងអ៊ីមែលផ្ញើទៅ meetings@erg.com។ សំណើនានាត្រូវតែដាក់ជូនក្នុងរយៈពេល 48 ម៉ោងមុនពេលកិច្ចប្រជុំចាប់ផ្តើម។
ដើម្បីទទួលបានព័ត៌មាននេះជាភាសាអង់គ្លេសអក្សរពុម្ពធំ ឬអក្សរស្ទាបសម្រាប់មនុស្សពិការភ្នែក សូមហៅទូរសព្ទទៅលេខ 1-877-623-6765។ TTY: 1877-623-7773។

ក្រុមប្រឹក្សា EJ ដំណើរការនៅក្រោមច្បាប់កិច្ចប្រជុំបើកចំហ [https://www.mass.gov/the-open-meeting-law]
និងស្វាគមន៍សមាជិកសាធារណជនដែលមានបំណងពិនិត្យមើលកិច្ចប្រជុំផ្លូវការរបស់ខ្លួន។
នៅអំឡុងពេលកិច្ចប្រជុំ អ្នកសង្កេតការណ៍អាចបញ្ចេញមតិយោបល់ ឬសំណួរទៅកាន់ក្រុមប្រឹក្សា EJ ដោយមានការអនុញ្ញាតពីប្រធាន។
ប្រសិនបើលោកអ្នកត្រូវការការបកប្រែភាសាជាភាសាដែលមិនមានខាងលើ
ឬការសម្របសម្រួលបន្ថែមណាមួយ សូមបញ្ជូនសំណើនោះក្នុងអ៊ីម៉ែលទៅតាម meetings@erg.com.
សំណើត្រូវតែដាក់ជូនពិនិត្យ 48 ម៉ោងមុនពេលចាប់ផ្តើមកិច្ចប្រជុំ។

ព័ត៌មានបន្ថែមអំពីក្រុមប្រឹក្សា EJ៖
ក្រុមប្រឹក្សា EJC ត្រូវបានតែងតាំងដោយអភិបាលក្រុង ដើម្បីណែនាំនិងផ្តល់អនុសាសន៍ដល់លេខាធិការ EEA អំពីគោលការណ៍និងស្តង់ដារពាក់ព័ន្ធ ដើម្បីសម្រេចបាននូវគោលការណ៍យុត្តិធម៌បរិស្ថាន។
គោលការណ៍បែបនេះ ត្រូវបានកំណត់ដោយច្បាប់រដ្ឋថាជា
"គោលការណ៍ដែលគាំទ្រការការពារពីការបំពុលបរិស្ថាន និងសមត្ថភាពក្នុង ការរស់នៅក្នុងបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនគិតពីជាតិសាសន៍ ពណ៌សម្បុរ ប្រាក់ចំណូល វណ្ណៈ ពិការភាព អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ ដើមកំណើតជនជាតិ ជនជាតិភាគតិច ឬពូជពង្ស
ជំនឿសាសនាឬជំនាញភាសា អង់គ្លេស ដែលរួមមាន៖ (i)
ការចូលរួមដ៏មានអត្ថន័យរបស់ប្រជាពលរដ្ឋទាំងអស់ទាក់ទងនឹងការអភិវឌ្ឍន៍ ការអនុវត្ត
និងការអនុវត្តច្បាប់បរិស្ថាន បទប្បញ្ញត្តិនិងគោលនយោបាយ
រួមទាំងគោលនយោបាយការប្រែប្រួលអាកាសធាតុ និង (ii) ការបែងចែកដោយសមធម៌នៃថាមពល

និងអត្ថប្រយោជន៍បរិស្ថាន និងបន្ទុកបរិស្ថាន។ ច្បាប់នេះ មានចែងនៅផ្នែក (Section 62L) តាមតំណភ្ជាប់នេះ៖ [https://malegislature.gov/Laws/SessionLaws/Acts/2021/Chapter8].

ព័ត៌មានបន្ថែមអំពីក្រុមប្រឹក្សា EJC របៀបវារៈនៃកិច្ចប្រជុំនាពេលខាងមុខ និងការកត់ត្រាកិច្ចប្រជុំកន្លងមក អាចរកបាន នៅទីនេះ៖ www.mass.gov/orgs/environmental-justice-council. សូមចុច "ជ្រើសរើសភាសា" ("Select Language") នៅខាងស្តាំខាងលើនៃគេហទំព័រ ដើម្បីបកប្រែទំព័រនេះ។

សូមអរគុណ

María Belén Power
អនុលេខាធិការយុត្តិធម៌ & សមធម៌បរិស្ថាន
ការិយាល័យប្រតិបត្តិផ្នែកថាមពល និងកិច្ច ការ បរិស្ថាន